# ហេតុអ្វីសេវាSMS Blasting មានសារសំខាន់សម្រាប់អាជីវកម្ម នៅកម្ពុជា?

នៅក្នុងចំណោមវិធីសាស្ត្រធ្វើទីផ្សារនានា សេវាកម្ម SMS Blasting គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត នៅកម្ពុជាដើម្បីជូនដំណឹងដល់អតិថិជនអំពីប្រូម៉ូសិនតាមរដូវកាល ការសម្ពោធផលិតផល និងសេវាកម្មថ្មីៗ និងការជូនដំណឹងសំខាន់ៗ ដល់ក្រុមមនុស្ស ដែលបានគ្រោងទុកជាមុន ។ ជាឧទាហរណ៍ សេវានេះ អាចត្រូវបានប្រើដោយគ្រឹះស្ថានអប់រំដើម្បីប្រកាសពីកម្មវិធីសិក្សាថ្មីៗរបស់សាលា ឬព័ត៌មានសំខាន់ៗផ្សេងទៀត ដល់លោកគ្រូអ្នកគ្រូ បុគ្គលិកសិក្សា និងសិស្សនិស្សិត។ សេវា SMS Blasting ធានាបានថា សាររបស់លោកអ្នក នឹងផ្ញើទៅដល់បុគ្គលទាំងនោះ ខណៈដែលវិធីសាស្ត្រដទៃដូចជាហ្វេសប៊ុកជាដើម ពុំអាចធ្វើបាន ។




អាជីវកម្មមួយចំនួន ព្យាយាមផ្ញើសារជាច្រើន ទៅកាន់អតិថិជនគោលដៅរបស់ខ្លួនម្តងមួយ តាមរយៈការសរសេរសារ និងផ្ញើទៅកាន់ទូរសព្ទដៃរបស់អតិថិជន។ វិធីនេះ ទាមទារឱ្យមានការខិតខំខ្លាំង ចំណាយពេលវេលា និងថវិកាច្រើន បើ

ធៀបនឹងការប្រើប្រាស់សេវា SMS Blasting របស់មេគង្គណិត ។ សេវា SMS Blasting មានលក្ខណៈខុសពីការផ្ញើសារម្តងមួយ សេវានេះ គឺជាវិធីសាស្ត្រផ្ញើសារលឿនរហ័សទាន់ចិត្ត ទៅកាន់អតិថិជនគោលដៅយ៉ាងងាយស្រួល ដោយសន្សំសំចៃពេលវេលា និងថវិកា ។ អ្វីដែលលោកអ្នកត្រូវធ្វើ គឺសរសេរត្រៀមនូវសារ ដែលលោកអ្នកចង់ផ្ញើទៅកាន់អតិថិជន និងបញ្ចូល(Upload) បញ្ជីទិន្នន័យលេខទូរសព្ទដៃរបស់អតិថិជន ចូលទៅក្នុងម៉ាស៊ីន API ហើយលោកអ្នកអាចផ្ញើសារទៅកាន់អតិថិជនរបស់ខ្លួន ក្នុងពេលតែមួយតាមរយៈបណ្តាញទូរសព្ទជាច្រើនបណ្តាញដូចជា (Smart, Cellcard, Metfone និងបណ្តាញទូរសព្ទដទៃទៀត.....) ។

សេវា SMS Blasting អាចហុចលទ្ធផលគាប់ប្រសើរ ជាពិសេសការធ្វើប្រូម៉ូសិន សម្រាប់អតិថិជន ដែលជាសមាជិក ឬអតិថិជន ដែលនិយមគាំទ្រប្រើផលិតផល ឬសេវារបស់លោកអ្នក ។ អាជីវកម្ម អាចទទួលបានអត្ថប្រយោជន៍ជាច្រើន និងបង្កើនប្រាក់ចំណូល តាមរយៈការប្រើប្រាស់ទិន្នន័យរបស់អតិថិជន ដែលមានស្រាប់ ដែលពួកគេប្រមូលបានពីកម្មវិធីជួបជុំសមាជិកភាព និងកម្មវិធីសំខាន់ៗនានា ដើម្បីផ្ញើសារអំពីប្រូម៉ូសិនដោយផ្ទាល់ ទៅកាន់ក្រុមអតិថិជន ដែលមានចំណាប់អារម្មណ៍លើសេវា ឬផលិតផលរួចហើយ ដើម្បីឱ្យពួកគាត់អញ្ជើញមកកាន់ហាងរបស់លោកអ្នកម្តងទៀត ទទួលយកប្រូម៉ូសិនបញ្ចុះតម្លៃ ឬជ្រាបពីការសម្ពោធលក់ផលិតផលថ្មីៗ និងការជូនដំណឹងផ្សេងៗ។



**តើលោកអ្នកបានជ្រាប ដែរ ឬទេថា** ក្រុមហ៊ុនធំៗជាច្រើន នៅទូទាំងសកលលោក បានដាក់បញ្ចូលសេវា SMS Blasting ចូលទៅក្នុងយុទ្ធសាស្ត្រធ្វើទីផ្សាររបស់ពួកគេ? ក្រុមហ៊ុនធំៗដូចជា Facebook, CNN, Express, IKEA, Reebok, Petco, និង Tommy Hilfiger បានប្រើសេវា SMS Blasting ដើម្បីពង្រីកវិសាលភាពអាជីវកម្មរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងចំណាយថវិកាតិច ។

អាជីវកម្មទាំងឡាយ អាចទទួលបានអត្ថប្រយោជន៍គាប់ប្រសើរពីការប្រើប្រាស់សេវា SMS Blasting របស់មេគង្គណិត ។ សេវានេះ គឺជាយុទ្ធសាស្ត្រធ្វើទីផ្សារដ៏មានប្រសិទ្ធភាពបំផុតមួយ ដើម្បីផ្ញើសារសំខាន់ៗ អំពីផលិតផល សេវា និង

ប្រូម៉ូសិននានា ទៅកាន់អតិថិជនគោលដៅ។ អ្វីដែលជាចំណុចខ្លាំងនៃសេវានេះគឺ បញ្ជូនសារទៅលឿនរហ័សទាន់ចិត្ត បត់បែនតាមស្ថានភាព ទៅដល់អតិថិជន  អត្រានៃការចុចមើលខ្ពស់ និងមានតម្លៃសមរម្យ។

សេវា MekongSMS របស់មេគង្គណិត ប្តេជ្ញាចិត្តខ្ពស់ក្នុងការជួយដល់អាជីវកម្មទាំងឡាយ នៅកម្ពុជា ឱ្យអាចបញ្ចូលនូវការធ្វើទីផ្សារតាមរយៈសេវា SMS ចូលទៅក្នុងយុទ្ធសាស្រ្តទីផ្សាររបស់ពួកគេ ដើម្បីទាញផលចំណេញឱ្យកាន់តែច្រើនពីការវិនិយោគផ្នែកទីផ្សារតាមរយៈវិធីធ្វើទីផ្សារ ដ៏សាមញ្ញ លឿនរហ័សទាន់ចិត្ត និងមានសុវត្ថិភាពខ្ពស់មួយនេះ ។ លើសពីនេះទៅទៀត តាមរយៈសមត្ថភាពផ្តល់ Branded Sender Name ដល់អាជីវកម្មរបស់លោកអ្នក សេវា SMS របស់មេគង្គណិត អាចជួយឱ្យអតិថិជន មើលឃើញពាណិជ្ជសញ្ញារបស់លោកអ្នកបានកាន់តែច្រើន និងធ្វើឱ្យអតិថិជនចងចាំពាណិជ្ជនាមរបស់លោកអ្នក នៅក្នុងចិត្ត នៅពេលដែលពួកគេ ត្រូវការជាវផលិតផល ឬសេវាជាក់លាក់ណាមួយ ។

### អំពីមេគង្គណិត

ចាប់តាំងពីឆ្នាំ ២០០៦ មក មេគង្គណិតទទួលបានអាជ្ញាប័ណ្ណជាក្រុមហ៊ុនផ្គត់ផ្គង់សេវាអ៊ីនធឺណិត (ISP) ក្រុមហ៊ុនផ្គត់ផ្គង់ការដោះដូរសេវាអ៊ីនធឺណិត (IXP) មជ្ឈមណ្ឌលដោះដូរទិន្នន័យអ៊ីនធឺណិត (IDX) ពីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា។ មេគង្គណិតផ្តល់ជូនសេវាយ៉ាងទូលំទូលាយស្របតាមតម្រូវការរបស់អតិថិជនរាប់ពីសេវាអ៊ីនធឺណិត និងសេវាតភ្ជាប់បណ្តាញនានាដូចជាសេវា IPLC/DPLC/VPN សេវា  cloud និង hosting សេវារក្សាទុកទិន្ន័យនៅមជ្ឈមណ្ឌលទីន្ន័យ សេវាគ្រប់គ្រង សេវាលក់ដុំ និងដំណោះស្រាយបច្ចេកវិទ្យាព័ត៌មាន ។ពិសេសជាងនេះទៅទៀត មេគង្គណិតមានសមត្ថភាពផ្តល់ជូនអ៊ីនធឺណិតហ្វាយប័រអុបទិកបច្ចេកវិទ្យាចុងក្រោយ ដែលមានល្បឿនលឿនដល់អតិថិជនសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម និងលំនៅឋាន ព្រមទាំងជំនួយផ្នែកបច្ចេកទេសលំដាប់ខ្ពស់ ដល់អតិថិជន ២៤ ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងសប្តាហ៍ និង ៣៦៥ ថ្ងៃក្នុងមួយឆ្នាំ ។

គេហទំព័រ៖ www.mekongnet.com.kh

### អំពី MekongSMS

មេគង្គណិត គឺជាក្រុមហ៊ុនផ្តល់សេវា SMS យូរជាងគេ និងទទួលបានទំនុកចិត្តខ្ពស់បំផុត នៅកម្ពុជា ។ ដោយបានសហការជាផ្លូវការ ជាមួយក្រុមហ៊ុនទូរគមនាគមន៍ទូរសព្ទចល័តទាំងអស់((Smart, Cellcard, Metfone, Seatel) MekongSMS មានសមត្ថភាពផ្ញើសារ SMS ទៅកាន់បណ្តាញទូរសព្ទចល័តទាំងអស់ នៅកម្ពុជា ។MekongSMS ផ្តល់ជូនសេវា ដែលមានសុវត្ថិភាព និងគួរជាទីទុកចិត្តបំផុត ដើម្បីផ្ញើកូដ OTP លេខកូដបញ្ជាក់( verification codes) ការជូនដំណឹងសំខាន់នានា និងការធ្វើទីផ្សារតាមរយៈសារ SMS ។ តាមរយៈច្រកផ្លូវច្រើន(routes)  ការគ្រប់គ្រង ២៤

ម៉ោង និងក្រុមជំនួយផ្នែកបច្ចេកទេសប្រកបដោយជំនាញវិជ្ជាជីវៈ ទើប MekongSMS ធានាបានថា សាររបស់លោកអ្នកត្រូវបានផ្ញើដល់អតិថិជនទាន់ពេលវេលា គ្រប់ពេល។

គេហទំព័រ៖ www.mekongsms.com

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់យើងខ្ញុំ តាមរយៈលេខ៖

Deskphone: 023 22 66 22

Mobile (Smart): 093 299 858

Mobile (Metfone): 097 610 3890

Mobile (Cellcard): 012 568 716

Facebook: MekongNet-Messenger

Telegram: MekongNet-Telegram

LinkedIn: MekongNet-Linkedin

Google Maps: MekongNet-Google-Map

Website: MekongNet-Website